# <u>សេចក្តីប្រកាសព័ត៌មាន</u>

**សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាបន្តកិច្ចសន្ទនាជាមួយតំណាងរាជរដ្ឋាភិបាលកម្ពុជា និងដាក់សម្ពោធជាផ្លូវការនូវយុទ្ធនាការ «ខ្ញុំទទួលយក» ដើម្បីលើកកម្ពស់ឱ្យមានសមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់ដៃគូអ្នកស្រឡាញ់ភេទដូចគ្នានៅប្រទេសកម្ពុជា**

**រាជធានីភ្នំពេញ ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២១**

ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២១ សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា (LGBT+) និងបណ្តាញដៃគូសង្គមស៊ីវិលនៅប្រទេសកម្ពុជាបានរៀបចំនូវ**កិច្ចសន្ទនាតុមូលមួយជាមួយនឹងតំណាងរាជរដ្ឋាភិបាលកម្ពុជា និងដាក់សម្ពោធជាផ្លូវការនូវយុទ្ធនាការ «ខ្ញុំទទួលយក»** ដើម្បីឱ្យមានសមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់ដៃគូអ្នកស្រឡាញ់ភេទដូចគ្នានៅប្រទេសកម្ពុជា។ **យុទ្ធនាការ «ខ្ញុំទទួលយក»** មានគោលបំណងបង្កើនការផ្សព្វផ្សាយការយល់ដឹង និងទទួលយកអ្នកស្រឡាញ់ភេទដូចគ្នាបន្ថែមទៀត ពីសំណាក់សាធារណជន ព្រមទាំងចូលរួមចំណែកលើកកម្ពស់ឱ្យមានកិច្ចការពារផ្លូវច្បាប់ចំពោះសមភាពអាពាហ៍ពិពាហ៍សម្រាប់ដៃគូអ្នកស្រឡាញ់ភេទដូចគ្នា ដែលស្របនឹងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងអនុសាសន៍នៃយន្តការពិនិត្យជាសកលតាមកាលកំណត់ (យូ.ភី.អ) ជុំទីបី។

**កិច្ចសន្ទនាតុមូល** និងការដាក់សម្ពោធជាផ្លូវការនូវយុទ្ធនាការ **«ខ្ញុំទទួលយក»** នៅក្នុងទិវាសិទ្ធិមនុស្សអន្តរជាតិឆ្នាំ២០២១ នេះ នឹងប្រព្រឹត្តទៅនៅសណ្ឋាគារហ៊ីម៉ាវ៉ារី សហការរៀបចំដោយ សហគមន៍ឥន្ទធនូកម្ពុជា និងបណ្តាញដៃគូសង្គមស៊ីវិលចូលរួមជាលក្ខណៈបុគ្គល ក្រុម និងស្ថាប័ន រួមមាន វុធ លីណូ ប្រធានផ្នែកសិល្បៈនៃគម្រោងសិល្បៈស ស ក្រុមរបាំបុរាណនិងសហសម័យឱក ព្រហ្មសុជន្ទ្រះនិងនាដ្យរស ក្រុមយុវជនស្ម័គ្រចិត្ត ក្តីស្រឡាញ់គឺចម្រុះ មូលនិធិមីក្រូឥន្ទធនូអន្តរជាតិកម្ពុជា មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា អង្គការថែទាំសុខភាពគ្រួសារកម្ពុជា(រ៉ាក់) អង្គការយេនឌ័រនិងអភិវឌ្ឍន៍ដើម្បីកម្ពុជា និងសមាគមចាសអាស៊ី អាគ្នេយ៍ជាដើម។

ការទទួលបានសិទ្ធិស្មើគ្នាចំពោះអាពាហ៍ពិពាហ៍ស្របច្បាប់ នៅតែជាអាទិភាពរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា ដើម្បីទទួលបានការការពារនូវអាពាហ៍ពិពាហ៍និងគ្រួសាររបស់ខ្លួន[1]។ **កិច្ចសន្ទនាតុមូល** មានគោលបំណងបន្តនូវការពិភាក្សារវាងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានិងតំណាងរាជរដ្ឋាភិបាលកម្ពុជា **អំពីដំណើរឆ្ពោះទៅមុខក្នុងការលើកកម្ពស់ឱ្យមានការទទួលស្គាល់និងការការពារផ្នែកច្បាប់នៃសមភាពអាពាហ៍ពិពាហ៍សម្រាប់អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា** ដោយស្របទៅតាមអនុសាសន៍នៃយន្តការពិនិត្យជាសកលតាមការកំណត់ (យូ.ភី.អ)ជុំទី៣ ក្នុងការ«**វិសោធនកម្ម មាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីអនុញ្ញាតឱ្យមានសមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់ដៃគូអ្នកស្រឡាញ់ភេទដូចគ្នា**» ដែល កម្ពុជាបានទទួលយកនៅក្នុងឆ្នាំ២០១៩។

**កិច្ចសន្ទនាតុមូលនេះ:** មានការចូលរួមប្រមាណ ៨៥នាក់ រាប់ទាំងពីតំណាងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងក្រសួងពាក់ព័ន្ធសំខាន់ៗរបស់ រាជរដ្ឋាភិបាលកម្ពុជា អាជ្ញាធរមូលដ្ឋាន សមាជិកសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា

---

[1] បច្ចុប្បន្ន នៅក្នុងមាត្រា៤៥នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់អាពាហ៍ពិពាហ៍រវាង «ប្តីមួយ ប្រពន្ធមួយ» ដែលបានផាត់ចេញដៃគូអ្នកស្រឡាញ់ភេទដូចគ្នា។ ទោះបីជាមិនមានច្បាប់ហាមឃាត់អាពាហ៍ពិពាហ៍ដៃគូអ្នកស្រឡាញ់ភេទដូចគ្នាជាក់លាក់ក៏ដោយ ក៏មិនមានការចែងណាមួយដែលសម្រួលទៅដល់អាពាហ៍ពិពាហ៍ដៃគូអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងច្បាប់កម្ពុជាដែរ។ សព្វថ្ងៃដៃគូអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាអាចរៀបចំពិធីក្រៅផ្លូវការនិងពិធីជប់លៀងជាដើម ប៉ុន្តែពួកគេមិនអាចចុះសំបុត្រអាពាហ៍ពិពាហ៍ និងមិនអាចទទួលបានការទទួលស្គាល់ផ្នែកច្បាប់នៃទំនាក់ទំនង អាពាហ៍ពិពាហ៍របស់ពួកគេបានទេ។

និងក្រុមគ្រួសាររបស់ពួកគេ ព្រមទាំងតំណាងបណ្ដាញដៃគូអង្គការសង្គមស៊ីវិល។ កិច្ចសន្ទនានេះគឺជាការពិភាក្សាបន្តពីឆ្នាំ២០១៨ ២០១៩ និងក្នុងខែកញ្ញា ឆ្នាំ២០២១ កន្លងទៅថ្មីៗ អំឡុងពេលការរៀបចំរបាយការណ៍ យូ.ភី.អ ពាក់កណ្ដាលអាណត្តិ។

*«វាពិតជាមានសារៈសំខាន់ណាស់ក្នុងការជម្រាបជូនដល់តំណាងរាជរដ្ឋាភិបាលរបស់យើងនិងសាធារណជនថា ដៃគូអ្នកស្រឡាញ់ភេទដូចគ្នាក៏ដូចជាពលរដ្ឋទូទៅដែរ គឺមានបំណងរៀបការជាមួយមនុស្សដែលខ្លួនស្រឡាញ់ កសាងគ្រួសារអនុវត្តតាមវប្បធម៌ប្រពៃណីខ្មែរយើង ហើយអាចទទួលបាននូវសំបុត្រអាពាហ៍ពិពាហ៍។ ដូច្នេះគ្រួសាររបស់យើងមានការទទួលស្គាល់ និងការការពារស្មើគ្នាតាមផ្លូវច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។»*~ កញ្ញា លី ពិសី ប្រធានសម្របសម្រួលសហគមន៍ឥន្ទធនូកម្ពុជា។

បន្ទាប់ពីកិច្ចសន្ទនាតុមូល នៅក្នុងថ្ងៃដដែល សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាក៏បានសម្ពោធជាផ្លូវការនូវយុទ្ធនាការ **«ខ្ញុំទទួលយក»**។ យុទ្ធនាការ **«ខ្ញុំទទួលយក»** នឹងបង្ហាញនូវសម្លេង បទពិសោធន៍ និងរឿងរ៉ាវរបស់សមាជិកសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ក្រុមគ្រួសារ ឪពុកម្ដាយរបស់ពួកគេ និងបណ្ដាញដៃគូការងារមកពីគ្រប់វិស័យទាំងអស់ ព្រមទាំងសាធារណជនទូទាំងប្រទេសកម្ពុជា តាមរយៈសារព័ត៌មាន និងបណ្ដាញព័ត៌មានសង្គម ដើម្បីឱ្យមានការយល់ដឹង ការទទួលយក និងការគាំទ្របន្ថែមទៀត ចំពោះសារៈសំខាន់នៃទទួលបាននូវសមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់ដៃគូអ្នកស្រឡាញ់ភេទដូចគ្នា នៅប្រទេសកម្ពុជា។ ចំពោះសេចក្ដីលម្អិតអំពីយុទ្ធនាការនេះ សូមចូលទៅគេហទំព័រ www.rockcambodia.org/iaccept.

*«ខ្ញុំនិងដៃគូរបស់ខ្ញុំបានរស់នៅជាមួយគ្នាដប់ឆ្នាំហើយ។ ពួកខ្ញុំបានកសាងគ្រួសារដ៏តូចមួយនេះកើតចេញពីក្ដីស្រឡាញ់ដ៏ស្មោះស្ម័គ្រពិតប្រាកដ ប្ដេជ្ញាចិត្តមើលថែរក្សាគ្នា មានអធ្យាស្រ័យចំពោះគ្នាទៅវិញទៅមក និងចិញ្ចឹមបីបាច់ថែរក្សាកូនប្រុសម្នាក់ផងដែរ។ ឪពុកម្ដាយ អ្នកជិតខាង និងអាជ្ញាធរសុទ្ធតែដឹងឮពីទំនាក់ទំនងគ្រួសាររបស់ពួកខ្ញុំ។ ប៉ុន្តែអាជ្ញាធរមិនអាចចេញសំបុត្រអាពាហ៍ពិពាហ៍ទទួលស្គាល់គ្រួសាររបស់ពួកខ្ញុំជាផ្លូវការឡើយ ព្រោះពួកខ្ញុំគឺជាអ្នកស្រឡាញ់ភេទដូចគ្នា។ ខ្ញុំមានការព្រួយបារម្ភខ្លាំងណាស់ ជាពិសេសគឺកូនរបស់ពួកខ្ញុំដែលគ្រួសារមួយនេះមិនមានការទទួលស្គាល់និងការពារដោយច្បាប់ដូចគ្រួសារដទៃ។ »* ~ ពៅ ដាលីន សមាជិកសហគមន៍ឥន្ទធនូកម្ពុជា។

*«ខ្ញុំស្រឡាញ់និងទទួលយកកូនរបស់ខ្ញុំ។ បំណងប្រាថ្នារបស់ខ្ញុំគឺឃើញកូនអាចរៀបការជាមួយនឹង មនុស្សដែលគេស្រឡាញ់ពិតប្រាកដ។ សុភមង្គលរបស់កូនខ្ញុំគឺជាសេចក្ដីសុខរបស់ខ្ញុំក្នុងនាមជាម្ដាយ។ ខ្ញុំសង្ឃឹមថារាជរដ្ឋាភិបាលកម្ពុជានឹងអនុញ្ញាតឱ្យដៃគូអ្នកស្រឡាញ់ភេទដូចគ្នាមានសិទ្ធិរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ ដូចដៃគូអ្នកស្រឡាញ់ភេទផ្ទុយគ្នាដទៃទៀតដែរ រស់នៅក្នុងជីវិតភាពដ៏សាមញ្ញ មានសុភមង្គល និងកក់ក្ដៅ។»* ~ សួស ណារិន ម្ដាយរបស់អ្នកស្រឡាញ់ភេទដូចគ្នា។

*«ដៃគូរបស់ខ្ញុំក៏ដូចជាដៃគូអ្នកស្រឡាញ់ភេទដូចគ្នារាប់ពាន់គូទៀតបានតស៊ូជំនះរាល់ឧបសគ្គរហូតបានរួមរស់កសាងគ្រួសារ និងមើលថែរក្សាគ្នា ទាំងគ្រាដែលលំបាក និងរីករាយ។ ដោយសារការតាំងចិត្ត និងភាពអំណត់ទាំងនេះធ្វើឱ្យឪពុកម្ដាយរបស់ពួកខ្ញុំ និងសហគមន៍ទទួលយក។ តើពួកខ្ញុំត្រូវបន្តរង់ចាំរហូតដល់ពេលណាទើបច្បាប់ឈប់ចាត់ទុកដៃគូនិងគ្រួសាររបស់ពួកយើងជាសាច់ដទៃទៀត? »*។ ~ គុយ ធីតា សមាជិកស្ថាបនិកនៃក្រុមក្ដីស្រឡាញ់គឺចម្រុះ។

###

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង

សាយ សៀកឡាយ ប្រធានសម្របសម្រួលយុទ្ធនាការ នៃសហគមន៍ឥន្ទធនូកម្ពុជា (រ៉ក់)

ទូរស័ព្ទ៖ ០១៧ ៧២៧ ៣៣៣ |អ៊ីមែល៖ contact@rockcambodia.org

គេហទំព័រ៖ www.rockcambodia.org/iaccept ហ្វេសប៊ុក៖ ខ្ញុំទទួលយក | @iacceptMEK